ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃការចូលរួមរបស់គណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ក្នុងមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ (AIPA-46) នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

**អគ្គលេខាធិការដ្ឋានរដ្ឋសភា** មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា) លើកទី៤៦ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់ **ឯកឧត្តមបណ្ឌិត តាន់ស្រ៊ី ដាតូ ហ្សូហារី ប៊ីន អាប់ឌុល** (Tan Sri Dato (Dr.) Johari Bin Abdul) ប្រធានរដ្ឋសភាប្រទេសម៉ាឡេស៊ី និងជាប្រធានអន្តរសភាអាស៊ាន(អាយប៉ា/AIPA)លើកទី៤៦ ដើម្បីពង្រឹងសាមគ្គីភាព និងមជ្ឈភាពអាស៊ានក្នុងការថែរក្សាសុខសន្តិភាព និងការអភិវឌ្ឍនៅក្នុងតំបន់។

អាយប៉ា ជាវេទិកាស្ថាប័ននីតិប្បញ្ញត្តិនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ មហាសន្និបាតអាយប៉ាប្រារព្ធឡើងជារៀងរាល់ឆ្នាំ ជាវេទិកាសភាសំខាន់ដែលផ្តល់ឱកាសដល់តំណាងរាស្ត្រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជួបជុំគ្នាដើម្បីពិភាក្សា ផ្លាស់ប្តូរមតិយោបល់ លើសេចក្តីព្រាងសេចក្តីសម្រេចក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម ស្ត្រី សមាជិកសភាវ័យក្មេង សម្រាប់ដាក់ជូនអង្គនីតិប្រតិបត្តិអាស៊ាន ពិចារណាដាក់បញ្ចូលក្នុងគោលនយោបាយដឹកនាំ ជំរុញការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងវិបុលភាព ដោយយកប្រជា-ពលរដ្ឋជាស្នូល ។

អំឡុងពេលចូលរួមមហាសន្និបាតអាយប៉ាលើកទី៤៦**សម្តេចប្រធានរដ្ឋសភា** និងសមាជិកសមាជិកាគណៈប្រតិភូទាំងអស់បានអញ្ជើញចូលរួមវេទិកា និងកិច្ចប្រជុំពាក់ព័ន្ធយ៉ាងសកម្ម និងប្រកបដោយផ្លែផ្កា ព្រមទាំងបានជួបជាមួយគណៈប្រតិភូសភាប្រទេសដទៃទៀតក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគីសំដៅពង្រឹងវិស័យការទូតសភា ការភ្ជាប់ទំនាក់ទំនងប្រទេសនិងប្រទេស សភានិងសភា ប្រជាជននិងប្រជាជនដើម្បីសន្តិភាព និងវិបុលភាពរួម។

### ១) ក្របខណ្ឌមហាសន្និបាតអាយប៉ាលើកទី៤៦

មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ ដែលរដ្ឋសភាប្រទេសម៉ាឡេស៊ីធ្វើជាម្ចាស់ផ្ទះ បានប្រារព្ធពិធីបើកជាផ្លូវការ យ៉ាងអធិកអធម នៅព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត តាន់ស្រ៊ី ដាតូ ហ្សូហារី ប៊ីន អាប់ឌុល** ( Tan Sri Dato ( Dr. ) Johari Bin Abdul ) ប្រធានរដ្ឋសភាប្រទេសម៉ាឡេស៊ី និងជាប្រធានអន្តរសភាអាស៊ាន(អាយប៉ា/AIPA) លើកទី៤៦ ឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម ( Dato' Seri Anwar bin Ibrahim ) នាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី ដោយមានប្រធានសភា អនុប្រធានសភាប្រទេសសមាជិកអាស៊ាន សភាព្រុយណេដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា ឥណ្ឌូនេស៊ី ឡាវ ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម ព្រមទាំងប្រតិភូសភាសង្កេតការណ៍អាយប៉ា ដៃគូអភិវឌ្ឍន៍ និងភ្ញៀវរបស់ម្ចាស់ផ្ទះរៀបចំមហាសន្និបាត សរុបប្រមាណ៩០០នាក់។

**សម្តេចរដ្ឋសភាធិបតី** បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ ដើម្បីពិភាក្សានិងអនុម័តសកម្មភាពនិងរបៀបវារៈនៃមហាសន្និបាត បានថ្លែងសុន្ទរកថាគន្លឹះក្នុងវេទិកាអ្នកដឹកនាំនយោបាយស្ត្រីវ៉ាយប៉ាលើកទី២ ( WAIPA Women Political Leaders Forum ) ជួបសវនាការជាមួយប្រធានរដ្ឋសភាម្ចាស់ផ្ទះ កិច្ចប្រជុំពេញអង្គមហាសន្និបាតទាំងពីរលើក ពិធីចុះហត្ថលេខាលើរបាយការណ៍បូកសរុបលទ្ធផល ពិធីបិទមហាសន្និបាត និងជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំសភាប្រទេសផ្សេងទៀត។

ដោយឡែក **សមាជិកគណៈប្រតិភូ** ដែលត្រូវបានចាត់តាំងចូលរួមកិច្ចប្រជុំគណៈកម្មាធិការទាំង៧របស់អាយប៉ា រួមមាន៖ កិច្ចប្រជុំសមាជិកសភាស្ត្រីអាយប៉ា (WAIPA) កិច្ចប្រជុំសមាជិកសភាវ័យក្មេងអាយប៉ា (YPA) កិច្ចប្រជុំគណៈកម្មាធិការកិច្ចការនយោបាយ គណៈកម្មាធិការកិច្ចការសេដ្ឋកិច្ច គណៈកម្មាធិការកិច្ចការសង្គមកិច្ច គណៈកម្មាធិការរៀបចំ និងគណៈកម្មាធិការបូកសរុប ព្រមទាំងបានទទួលជំនួបទល់មុខរវាងអគ្គលេខាធិការអាយប៉ានិងអាស៊ាន និងកិច្ចសន្ទនាជាមួយសភាសង្កេតការណ៍អាយប៉ាចំនួន ១៤ ប្រទេស។

ក្នុងសុន្ទរកថាគន្លឹះថ្លែងទៅកាន់វេទិកាអ្នកដឹកនាំនយោបាយស្ត្រី WAIPA **សម្តេចរដ្ឋសភាធិបតី** បានលើកឡើងពីតួនាទីដ៏សំខាន់របស់ស្ត្រីលើការងារសង្គម និងនយោបាយ ជាពិសេស ការជំរុញសន្តិភាព យុត្តិធម៌ បរិយាបន្នសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការពង្រឹងសន្តិសុខមនុស្សជាតិ។ រដ្ឋសភាកម្ពុជា បានអនុម័តច្បាប់នានាដែលគាំទ្រដល់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងបានបង្កើតក្រុមសមាជិកសភាស្ត្រីដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកសភាស្ត្រី និងលើកកម្ពស់សំឡេងស្ត្រី ព្រមទាំងបានផ្តួចផ្តើមយុទ្ធនាការ #Girl2Leader ដើម្បីផ្តល់ឱកាសដល់ស្ត្រីនិងក្មេងស្រីបានរៀនសូត្រពីបទពិសោធន៍ដឹកនាំ និងការចូលរួមក្នុងវិស័យនយោបាយ។

នៅក្នុងសេចក្តីថ្លែងការណ៍ទៅកាន់កិច្ចប្រជុំពេញអង្គលើកទី១ **សម្តេចរដ្ឋសភាធិបតី** អំពាវនាវកុំប្រើ **"ច្បាប់ព្រៃ និងអនុវត្តច្បាប់អាជ្ញាសឹក"** នៅក្រៅដែនដីរបស់ខ្លួន ដែលជាការរំលោភបំពានលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់ប្រទេសដទៃ។ សម្តេចប្រធានរដ្ឋសភា បានលើកឡើងថា ទោះបីបទឈប់បាញ់បានចូលជាធរមាន តាំងពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥មកម្លេះ តែសកម្មភាពរំលោកបំពានពីភាគីថៃកើតមានជាបន្តបន្ទាប់ រួមមានការបន្តឃុំខ្លួនទាហានកម្ពុជា ១៨នាក់ ដោយខុសច្បាប់ ធ្វើជាចំណាប់ខ្មាំង ប៉ុន្មានម៉ោងក្រោយបទឈប់បាញ់បានចូលជាធរមាន និងករណីវាយលួសបន្លាខុសច្បាប់ និងសកម្មភាពនានាដែលរំខានដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ និងបានរំលោភបំពានម្តងហើយម្តងទៀតមកលើដែនអធិបតេយ្យកម្ពុជា។ ជាក់ស្តែកាលពីថ្ងៃទី១៧ ខែកញ្ញាកន្លងទៅនេះ កងយោធាថៃបានប្រើប្រាស់កម្លាំងមកលើប្រជាជនស្លូតត្រង់របស់កម្ពុជា ដែលបណ្តាលឱ្យមានអ្នករងរបួសជាង២០នាក់ ។

**សម្តេចរដ្ឋសភាធិបតី** បានអំពាវនាវឱ្យភាគីថៃ ត្រូវតែបញ្ឈប់ជាបន្ទាន់នូវការប្រើប្រាស់កម្លាំងយោធាប្រឆាំងនឹងជនស៊ីវិល និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជាជនកម្ពុជាជាបន្តទៅទៀត។ ការកសាងទំនុកចិត្តគ្នាទៅវិញទៅមក ទាមទារឱ្យមានការខិតខំប្រឹងប្រែងពីភាគីទាំងពីរ ដោយមានសុច្ឆន្ទៈ និងភាពស្មោះត្រង់ពិតប្រាកដ។ ភាគីដែលរំលោភបំពានលើបទឈប់បាញ់ ត្រូវតែទទួលការថ្កោលទោស ឬការដាក់ទណ្ឌកម្មជាដាច់ខាត។ សម្តេចបានអំពាវនាវ ដល់សហគមន៍អន្តរជាតិ ជួយបន្តតាមដានជាប្រចាំនូវការវិវឌ្ឍ នៃការអនុវត្តបទឈប់បាញ់ និងធ្វើការវាយតម្លៃដោយខ្លួនឯង ផ្អែកលើតថភាពជាក់ស្តែង។ ក្នុងន័យនេះ ចាំបាច់ត្រូវមានបេសកកម្មស្វែងរកការពិតជាអន្តរជាតិជាបន្ទាន់។ "ខ្ញុំពិតជាមានការព្រួយបារម្ភយ៉ាងខ្លាំងថា ការបន្តរំលោភបំពានលើបទឈប់បាញ់ នឹងបណ្តាលឱ្យបាត់បង់ទំនុកចិត្តផ្នែកនយោបាយ និងការផ្ទុះឡើងវិញនៃជម្លោះប្រដាប់អាវុធ ដែលនឹងបង្កផលវិបាកដល់ប្រជាជាតិទាំងពីរ"។

ជាមួយគ្នានេះ សម្តេចប្រធានរដ្ឋសភាក៏បានអំពាវនាវឱ្យបញ្ឈប់ការប្រើប្រាស់កម្លាំងយោធាដើម្បីបោះបង្គោលព្រំដែនជាឯកតោភាគី ដោយទុកភារកិច្ចស្របច្បាប់នេះ ឱ្យគណៈកម្មការព្រំដែនចម្រុះ(JBC) និងយន្តការមានស្រាប់នានា តាមមធ្យោបាយសន្តិវិធី ផ្អែកលើកិច្ចព្រមព្រៀងដែលមានស្រាប់ និងច្បាប់អន្តរជាតិ។

សមាជិកគណៈប្រតិភូសភាកម្ពុជាក៏បានចូលរួមកិច្ចសន្ទនាវាងអាយប៉ានិងសភាសង្កេតការណ៍ចំនួន១៤ ប្រទេស ជាអាទិ៍ សភាតំណាងប្រជាជនចិន ជប៉ុន សាធារណរដ្ឋកូរ៉េ អូស្ត្រាលី ឥណ្ឌា តួកគី កាណាដា និងរុស្ស៊ី ជាដើម ក្រោមប្រធានបទ "មជ្ឈភាពអាស៊ានៈ ការកសាងនិម្មាបនកម្មតំបន់ប្រកបដោយបរិយាបន្នដើម្បីអនាគតមានចីរភាព"។ សកម្មភាពសំខាន់ៗរបស់គណៈប្រតិភូសភាកម្ពុជាផ្តោតលើ ការពង្រឹងការទូតសភា ដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន ជាពិសេសជំរុញកិច្ចសហប្រតិបត្តិការវាងអាយប៉ា និងសភាសង្កេតការណ៍ ដើម្បីសម្រេចគោលដៅ និងផលប្រយោជន៍រួម។

មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ បានបិទបញ្ចប់នៅរសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ ប្រកបដោយលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ ដោយបានអនុម័តជាឯកច្ឆន្ទនូវសេចក្តីសម្រេចចំនួន ៤២ ដែលក្នុងនោះ សេចក្តីព្រាងសេចក្តីសម្រេចដែលផ្តួចផ្តើមដោយកម្ពុជាមានចំនួនបី រួមមានៈ

**ទី១** សេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការជំរុញគំនិតផ្តួចផ្តើមសន្តិភាព ដើម្បីមនុស្សជាតិ និងភពផែនដី។ ការអនុម័តនេះ គឺជាការទទួលស្គាល់របស់អាយប៉ា ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៅក្នុងការស្វែងរកសន្តិភាព និងការពារ លើកកម្ពស់សុខសន្តិភាព ជូនពលរដ្ឋទាំងក្នុងប្រទេស និងក្រៅប្រទេស ដូចជាការអនុម័តនូវ ធម្មនុញ្ញសន្តិភាពដើម្បីប្រជាជន និងភពផែនដី ដែលប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងដាក់ចេញដោយ **សម្តេចតេជោ ហ៊ុន សែន** ត្រូវបានអនុម័តនៅសម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព ដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះ កាលពីខែវិច្ឆិកា ឆ្នាំ២០២៤។

**ទី២** សេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតវេទិកាថ្នាក់ដឹកនាំអាយប៉ា និង សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតភាពជាដៃគូអាយប៉ា ដើម្បីលើកកម្ពស់ការចូលរួមរបស់អាយប៉ាជាមួយដៃគូពាក់ព័ន្ធ សម្រាប់អាស៊ានប្រកបដោយបរិយាបន្ន និងចីរភាព មានគោលបំណងបង្កើតវេទិកាថ្នាក់

ដឹកនាំអាយប៉ា សំដៅលើកកម្ពស់កិច្ចសន្ទនាប្រកបដោយបរិយាបន្ន និងពហុភាគីលើបញ្ហាថ្មីៗ ក្នុងតំបន់ និងអន្តរជាតិ ក្នុងគោលបំណងកសាងការយល់ដឹងរួមគ្នា និងបង្កើតដំណោះស្រាយប្រកបដោយនវានុវត្តន៍ ដែលចាំបាច់ត្រូវមានភាពរហ័សរហួន សម្របខ្លួននិងមានគំនិតច្នៃប្រឌិតដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗទាំងនេះ ប្រកបដោយប្រសិទ្ធភាព។

**ទី៣** សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតភាពជាដៃគូអាយប៉ាដើម្បីពង្រឹងការចូលរួមរបស់សភាអាយប៉ា ជាមួយដៃគូខាងក្រៅសម្រាប់អាស៊ានប្រកបដោយបរិយាបន្ន និងចីរភាព មានគោលបំណងចម្បង គឺដើម្បីពង្រឹងការចូលរួមជាមួយសភាសង្កេតការណ៍ ដែលរួមចំណែកដល់បេសកកម្មរបស់អាយប៉ា ក្នុងការបង្កើតក្របខ័ណ្ឌរួម និងឆ្ពោះទៅអនាគត ដើម្បីលើកកម្ពស់ការទូតសភា ធ្វើឱ្យការចូលរួមជាមួយសភាសង្កេតការណ៍ និងអង្គការដៃគូកាន់តែស៊ីជម្រៅ និងដើម្បីពង្រឹងមជ្ឈភាពអាស៊ាន និងរួមចំណែកដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពស្របតាមទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ និងមូលបទអាស៊ានឆ្នាំ២០២៥ របស់ប្រទេសម្ចាស់ផ្ទះម៉ាឡេស៊ីគឺ "បរិយាបន្ន និងចីរភាព"។

ចំណែកសេចក្តីព្រាងសេចក្តីសម្រេច ដែលសភាកម្ពុជាជាសហគាំទ្រមានចំនួន១២ ក្នុងនោះគណៈកម្មាធិការកិច្ចការនយោបាយមានចំនួន១ គណៈកម្មាធិការសេដ្ឋកិច្ចមានចំនួន៤ គណៈកម្មាធិការសង្គមកិច្ចមានចំនួន២ កិច្ចប្រជុំសមាជិកសភាស្ត្រីអាយប៉ាមានចំនួន៣ កិច្ចប្រជុំសមាជិកសភាវ័យក្មេងអាយប៉ាមានចំនួន២។

មហាសន្និបាតអាយប៉ាលើកទី៤៦ បានជ្រើសតាំង ឯកឧត្តមបណ្ឌិត **ថែម វីឡាំ** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាអគ្គលេខាធិការនៃលេខាធិការដ្ឋានអាយប៉ា ក្នុងអាណត្តិរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦តទៅ។

មហាសន្និបាតបានសម្រេចបញ្ចូលសភាអាល់ហ្សេរី ជាសភាសង្កេតការណ៍អាយប៉ាផងដែរ។ រហូតមកដល់ពេលនេះ សភាសង្កេតការណ៍អាយប៉ា មានចំនួន២៦។ មុនបិទបញ្ចប់កិច្ចប្រជុំមហាសន្និបាត **សម្តេចរដ្ឋសភាធិបតី** និងប្រធានគណៈប្រតិភូសភាសមាជិកអាយប៉ា បានអញ្ជើញចុះហត្ថលេខាលើរបាយការណ៍បូកសរុបលទ្ធផលមហាសន្និបាតអាយប៉ាលើកទី៤៦។ **មហាសន្និបាតអាយប៉ាលើកទី៤៧** នឹងប្រារព្ធធ្វើនៅប្រទេសហ្វីលីពីន ក្នុងឆ្នាំ២០២៦។

**២-ជំនួបទ្វេភាគី**

- **សម្តេចរដ្ឋសភាធិបតី** បានអញ្ជើញពិភាក្សាការងារដាច់ដោយឡែកពីគ្នា ជាមួយ **ឯកឧត្តម តាន់ស្រ៊ី ដាតូ ហ្សូហារី អាប់ឌុល** (Tan Sri Dato Johari Abdul) ប្រធានរដ្ឋសភាប្រទេសម៉ាឡេស៊ី និងជាប្រធានអាយប៉ាលើកទី៤៦ ឯកឧត្តម អាវ៉ាង ប៊ីមី អាវ៉ាង អាលី បាសា (Awang Bemee Awang Ali Basah) ប្រធានព្រឹទ្ធសភាប្រទេសម៉ាឡេស៊ី ឯកឧត្តម **ជិន ថាញ់ មិន** (Tran Thanh Man) ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម លោកជំទាវ **សាហ៊ីបា ហ្គាហ្វារ៉ូវ៉ា** (Sahiba GAFAROVA) ប្រធានរដ្ឋសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ឯកឧត្តម KARA-OOL Shalban អនុប្រធានរដ្ឋសភាសហព័ន្ធរុស្ស៊ី លោកជំទាវ សុធន់ សាយ៉ាចាក់ (Sounthone XAYACHACK) អនុប្រធានរដ្ឋសភា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឯកឧត្តម ចាវីយើ អ៊ើចណាហ្ស៊ូ (Javier Ignacio Maroto Aranzabal)

អនុប្រធានរដ្ឋសភា ប្រទេសអេស្ប៉ាញ ឯកឧត្តម វ៉ូកធឺ បេកគី (Wouter Beke) ប្រធានគណៈប្រតិភូសភាអឺរ៉ុបទំនាក់ទំនងជាមួយបណ្តាប្រទេសអាស៊ីអាគ្នេយ៍ និងសមាគមអាស៊ាន និងជាសមាជិកសភាអឺរ៉ុប។

ជាមួយគ្នានេះ ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម កៃ ជីមីង (CAI Jiming) សមាជិកគណៈ-កម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនចិន និងបានជួបពិភាក្សាការងារជាមួយ ឯកឧត្តម (អូស្មាន់ សាកឡាម) **Osman Sağlam** ប្រធានក្រុមសភាតួកគី-AIPA ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងសភាទាំងពីរ និងរវាងសភាតួកគី ជាមួយនឹងតំបន់អាស៊ានផងដែរ។

នៅគ្រប់ជំនួបពិភាក្សាការងារ **សម្តេចរដ្ឋសភាធិបតី** បានថ្លែងអំពីភាពផុយស្រួយនៃការអនុវត្តបទឈប់បាញ់ ដោយសារភាគីថៃបាននិងកំពុងរំលោភបំពាន។ កម្ពុជាស្រឡាញ់សន្តិភាព ហើយជានិច្ចកាលអត់ធ្មត់ក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី គោរពធម្មនុញ្ញអង្គការសហប្រជាជាតិ គោរពធម្មនុញ្ញអាស៊ាននិងច្បាប់អន្តរជាតិ។ កម្ពុជាជំរុញឱ្យបង្កើតអ្នកសង្កេតការណ៍អាស៊ាន (AOT) និងពង្រាយទៅទីតាំងកើតហេតុឱ្យបានឆាប់រហ័ស និងសូមអំពាវនាវដល់អន្តរជាតិចូលរួមតាមដានបទឈប់បាញ់ឱ្យមានការអនុវត្តបានពេញលេញ សំដៅជានាការពារសុខសន្តិភាព ស្ថិរភាព និងសុវត្ថិភាព ដែលមិនត្រឹមតែបម្រើផលប្រយោជន៍ពលរដ្ឋប្រទេសទាំងពីរប៉ុណ្ណោះទេ តែជានាការពារសុខសន្តិភាព ក្នុងតំបន់ និងសកលលោកថែមទៀតផង។

ថ្នាក់ដឹកនាំស្ថាប័ននីតិប្បញ្ញត្តិ បានវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាព កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ការងារការទូតសភា ថាពិតជាមានតម្លៃ និងមានសារៈសំខាន់បំផុតនៅក្នុងបរិបទដែលពិភពលោកកំពុងប្រឈមនឹងហានិភ័យខ្ពស់ដូចជាការប្រទាញប្រទង់ភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និងការប្រឈមនឹងហានិភ័យពីសន្តិសុខមិនមែនប្រពៃណី ដូចជាជំងឺឆ្លងនិងការប្រែប្រួលអាកាសធាតុជាដើម។

បេសកកម្មការទូតរបស់សភាកម្ពុជានៅឆាកអន្តរជាតិប្រកបដោយបុរេសកម្ម ក្នុងការពង្រឹងពង្រីកចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ ដោយយកពលរដ្ឋជាស្នូល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃអាទិត្យ ១៤រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៥

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**